ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សេចក្តីប្រកាសព័ត៌មាន

រាជធានីភ្នំពេញ៖ ថ្ងៃទី ២៣ ខែធ្នូ ឆ្នាំ២០១៤ ដោយ អគ្គនាយកដ្ឋានពន្ធដារ

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពីពិធីជួបសំណេះសំណាលជាមួយនិស្សិតនៃវិទ្យាស្ថាន CAM-ED

នាវេលាម៉ោង ១៥:00 ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៤ វិទ្យាស្ថាន CAM-ED បានរៀបចំកម្មវិធីជួបសំណេះសំណាលជាមួយនិស្សិតនៃវិទ្យាស្ថាន។ ពិធីជួបសំណេះសំណាលនេះ ត្រូវបានប្រារព្ធធ្វើឡើងនៅសណ្ឋាគារ Raffle Le Royal ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ។

ជាកិច្ចចាប់ផ្តើម ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល បានថ្លែងអំណរគុណចំពោះលោក Casey Barnett ប្រធានវិទ្យាស្ថានដែលផ្តួចផ្តើមឲ្យមានកម្មវិធីជួបសំណាលនេះឡើង។ នេះគឺជាការជួបសំណាលលើកទីមួយបង្អស់ ដែលផ្តល់ឱកាសឲ្យនិស្សិតបានស្វែងយល់ពីរបត់នៃការកែទម្រង់របស់អគ្គនាយកដ្ឋានពន្ធដារ នារយៈពេលចុងក្រោយនេះ។ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលបានជម្រាបជូនប្អូនៗនិស្សិតទាំងនោះថា ផ្អែកតាមយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ អគ្គនាយកដ្ឋានពន្ធដារត្រូវរៀបចំយន្តការក្នុងការគ្រប់គ្រងប្រមូលពន្ធ ដោយផ្តោតជាសំខាន់លើមុខងារប្រតិបត្តិការស្នូល រួមមាន ការចុះបញ្ជីអ្នកជាប់ពន្ធ, ការផ្តល់សេវាអ្នកជាប់ពន្ធ, ការចាត់ចែងលិខិតប្រកាស,ការធ្វើសវនកម្ម,ការប្រមូលបំណុល និងបណ្តឹងតវ៉ា។





ក្នុងបរិបទនៃសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន (AEC) ដែលនឹងខិតចូលមកដល់ក្នុងឆ្នាំ២០១៥ ខាងមុខ ប្រទេសកម្ពុជាត្រូវបើកចំហទីផ្សារសេរី ដែលការអនុវត្តពន្ធគយក្នុងក្របខ័ណ្ឌអាស៊ាននឹងត្រូវថយចុះជាបន្តបន្ទាប់ ពោលគឺមិនមានបង់ពន្ធគយជាមួយប្រទេសក្នុងតំបន់អាស៊ានផង និងជាមួយមហាអំណាចចិនបន្ថែមផង។ ពេលនោះ ចំណូលពន្ធគយអាចនឹង

ធ្លាក់ចុះ ហើយបន្ទុកនៃការប្រមូលចំណូលពន្ធនឹងត្រូវធ្លាក់មកលើផ្នែកប្រមូលចំណូលពន្ធផ្ទៃក្នុងដែលជាដែនសមត្ថកិច្ចរបស់អគ្គនាយកដ្ឋានពន្ធដារ កាន់តែច្រើនឡើងៗ។

ឯកឧត្តមបានគូសបញ្ជាក់ថា ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ចំណូលពន្ធផ្ទៃក្នុងដែលជាដែនសមត្ថកិច្ចរបស់អគ្គនាយកដ្ឋានពន្ធដារ ដែលត្រូវបានកំណត់ដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង គឺតម្រូវឲ្យមានការកើនឡើងជាលំដាប់ និងជារៀងរាល់ឆ្នាំ ដោយកើនឡើងប្រមាណ **៨៩៣,៤១ លានដុល្លារ** ក្នុងរយៈពេលដប់ឆ្នាំចុងក្រោយនេះ ពោលគឺកើនឡើងពី **១០០,៣៨ លានដុល្លារ** នៅឆ្នាំ២០០៤ រហូតដល់ **៩៩៣,៧៩ លានដុល្លារ** នៅឆ្នាំ២០១៤ ហើយនឹងបន្តកើនឡើងរហូតដល់ **២០០០ លានដុល្លារ** នៅឆ្នាំ២០១៨។ ដូច្នេះក្នុងបរិបទនៃលំហូរពាណិជ្ជកម្ម និងលំហូរធនធានមនុស្សដោយសេរីក្នុងតំបន់ ចាប់ពីឆ្នាំ២០១៥នេះទៅ គឺទាមទារជាចាំបាច់នូវអ្នកមានចំណេះដឹងជ្រៅជ្រះពិតប្រាកដ មានគុណវុឌ្ឍិខ្ពស់ បម្រើការងារប្រកបដោយប្រសិទ្ធភាពនិងផលិតភាពខ្ពស់ ធ្វើការបម្រើជាតិទៅតាមសមត្ថភាពរបស់ខ្លួន សំដៅធ្វើយ៉ាងណា ប្រមូលចំណូលពន្ធបានគ្រប់តាមផែនការច្បាប់។

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលបានជម្រាបជូនប្អូនៗ ក្មួយៗនិស្សិត ក្នុងឱកាសនេះថា ក្នុងបរិបទសមាហរណកម្មសេដ្ឋកិច្ចអាស៊ាននេះដែរ អគ្គនាយកដ្ឋានពន្ធដារបាននិងកំពុងត្រៀមលក្ខណៈគ្រប់យ៉ាង ជាពិសេស ការពង្រឹងសមត្ថភាពផ្ទៃក្នុងរបស់មន្ត្រីដែលមានស្រាប់ និងសម្លឹងរកមើលធនធានមនុស្សថ្មីដែលមានគុណភាព តាមរយៈការផ្តល់កាលានុវត្តភាពការងារដល់អ្នកមានសមត្ថភាពទាំងឡាយ ដើម្បីជួយជំរុញល្បឿននៃកំណែទម្រង់របស់អគ្គនាយកដ្ឋានកាន់តែឆាប់បានទទួលជោគជ័យ ជាពិសេស គឺដើម្បីមានលទ្ធភាពប្រកួតប្រជែងនិងរត់ឲ្យទាន់គេឯងនៅក្នុងតំបន់ និងក្នុងពិភពលោក។

ឯកឧត្តមបានសង្កត់ធ្ងន់ថា បច្ចុប្បន្ននេះ និស្សិតយើងកាន់តែច្រើនឡើងៗបាននិងកំពុងនាំគ្នាបន្តការសិក្សាថ្នាក់សញ្ញាបត្រអនុបណ្ឌិត ឬសញ្ញាបត្រថ្នាក់បណ្ឌិត ពីព្រោះពួកគេយល់ថា ការរៀនបានតែកាន់ខ្ពស់គឺជាប្រការល្អសម្រាប់ជីវិតរបស់បុគ្គលខ្លួនឯង និងសម្រាប់សង្គមជាតិទាំងមូល។ ប៉ុន្តែបញ្ហានៅត្រង់ថា បរិមាណសញ្ញាបត្រមានច្រើនមែន ប៉ុន្តែគុណភាពអ្នកដែលទទួលបានសញ្ញាប័ត្រជាន់ខ្ពស់នៅមានកម្រិតទាប បើប្រៀបធៀបទៅនឹងការអប់រំជាមួយប្រទេសក្នុងតំបន់។ គុណភាពទាបនេះនឹងធ្វើឲ្យកម្លាំងពលកម្មរបស់យើងមិនអាចប្រកួតប្រជែងជាមួយកម្លាំងពលកម្មនៃបណ្តាប្រទេសនៅតំបន់អាស៊ានបានឡើយ។ សព្វថ្ងៃនេះ កម្ពុជាយើងមានបេក្ខជនជាច្រើនស្វែងរកការងារធ្វើ ប៉ុន្តែមិនសូវមានច្រើនទេ ធនធានមនុស្សប្រកបដោយគុណភាព ដែលនេះជាបញ្ហាប្រឈមរបស់យើង។

ឯកឧត្តមបានជម្រាបជូនក្មួយៗនិស្សិត ថា យើងនៅមានការខ្វះខាតធនធានមនុស្សល្អ ឬខ្វះកម្លាំងពលកម្មដែលមានគុណភាព ដែលធនធាននេះឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលសង្កត់ធ្ងន់លើជាធនធានមនុស្សដែលមានលក្ខណៈសម្បត្តិ ៦ យ៉ាង ដូចតទៅ÷ “(១)មានចំណេះដឹង និងជំនាញ, (២)មានបទពិសោធន៍ការងារ, (៣)មានសុជីវធម៌សង្គមល្អ មានស្វ័យគារវចំពោះអ្នកជុំវិញខ្លួន (Auto-respect) និងស្វ័យវិន័យ (Auto-discipline),(៤)ស្មោះត្រង់នឹងស្ថាប័នដែលខ្លួនធ្វើការ (៥) មានផលិតភាពខ្ពស់សម្រាប់ស្ថាប័នរបស់ខ្លួន និង (៦)មានការតាំងចិត្ត និងទទួលខុសត្រូវខ្ពស់ចំពោះការងារ។ ចំណុចទាំង៦នេះ គឺជាលក្ខណៈចាំបាច់ដែលគេហៅថា ធនធានមនុស្សល្អ។ មានតែចំណេះ ប៉ុន្តែខ្វះសីលធម៌សង្គម ខ្ជិលធ្វើការងារ គ្មានការទទួលខុសត្រូវចំពោះការងាររបស់ខ្លួន នោះគេមិនអាចហៅថាជា “ធនធានមនុស្សល្អ” បានទេ។

ឯកឧត្តមបានបញ្ជាក់បន្ថែមយ៉ាងដូច្នេះថា ឆ្លើយតបនឹងបរិបទសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន អគ្គនាយកដ្ឋានបាននិងកំពុងខិតខំកែលម្អមុខងារភារកិច្ចរបស់ខ្លួនឲ្យបានកាន់តែប្រសើរឡើងថែមមួយកម្រិតទៀត តាមរយៈការធ្វើឲ្យប្រសើរឡើងនូវសេវាសាធារណៈជូនដល់អ្នកជាប់ពន្ធគ្រប់មជ្ឈដ្ឋាន ព្រមជាមួយនោះ ក៏បាននិងកំពុងអប់រំណែនាំមន្ត្រីគ្រប់លំដាប់ថ្នាក់ ឲ្យផ្លាស់ប្តូរឥរិយាបថ និងបណ្តុះផ្នត់គំនិតថ្មី(Mindset) គោរពវិន័យការងារក្រមសីលធម៌វិជ្ជាជីវៈ បំពេញភារកិច្ចប្រកបដោយការទទួលខុសត្រូវខ្ពស់។ ព្រមជាមួយនេះ អគ្គនាយកដ្ឋានក៏កំពុងតែសម្លឹងរកធនធានមនុស្សល្អបន្ថែមទៀត

ដែលនេះគឺជាការផ្តល់ឱកាសថ្មី និងជាការលើកទឹកចិត្តចំពោះអ្នកមានសមត្ថភាពខ្ពស់ ស្របតាមគោលនយោបាយកែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាល ក៏ដូចជាការឆ្លើយតបទៅនឹងគោលការណ៍នៃការធ្វើទំនើបភាវូបនីយកម្ម វិស័យពន្ធដារ។




ជាទីបញ្ចប់ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល បានសម្តែងការកោតសរសើរ និងមានមោទនភាពយ៉ាងខ្លាំងដែលកូនខ្មែរជំនាន់ថ្មី ទទួលបានការអប់រំខ្ពស់ ជាមួយសញ្ញាបត្រដែលទទួលស្គាល់ជាលក្ខណៈអន្តរជាតិ។ នេះគឺជាសញ្ញាវិជ្ជមានថ្មីមួយទៀត នៃវិស័យធនធានមនុស្សខ្មែរ ដែលជាកម្លាំងចលករដ៏សំខាន់ក្នុងការរុញច្រានកម្ពុជាឲ្យចាកផុតពីភាពក្រីក្រ បានយ៉ាងឆាប់រហ័ស និងថា ប្អូនៗ ក្មួយៗទាំងអស់គ្នា គឺជាក្តីសង្ឃឹមថ្មី ជាកម្លាំងចលករថ្មីសម្រាប់ប្រទេសជាតិទាំងមូល ក្នុងការជួយអភិវឌ្ឍប្រទេសជាតិរបស់យើង។ ក្នុងនាមឯកឧត្តមផ្ទាល់ ឯកឧត្តមមានជំនឿយ៉ាងមុតមាំថា ជាមួយនឹងចំណេះដឹងជ្រៅជ្រះ និងជំនាញច្បាស់លាស់ ប្អូនៗ ក្មួយៗពិតជាទទួលបានការងារល្អ ជាមួយប្រាក់បៀវត្សសមរម្យ មានសីលធម៌ សុជីវធម៌សង្គមល្អ ពោលគឺជាធនធានមនុស្សល្អ ធនធានយ៉ាងកម្ររបស់ប្រទេសជាតិ និងជូនពរប្អូនៗ ក្មួយៗ សូមទទួលបានជោគជ័យក្នុងការសិក្សា និងប្រើប្រាស់ចំណេះដឹងដែលទទួលបាននេះ ទៅបម្រើជាតិមាតុភូមិ ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ជាមួយនឹងវិជ្ជាជីវៈខ្ពស់៕